01251265

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 06 / 2016
ម៉ោង (Time/Heure): 13 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E352/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

## អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ÷** **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី** ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦

**ពី÷** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង**
**ភាគីទាំងអស់នៃសំណុំរឿង ០០២, អង្គភាពគាំពារជនរងគ្រោះ (“VSS”)**
**មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ÷** **ការចង្អុលបង្ហាញគម្រោងសំណងសម្រាប់អនុវត្តនៅក្នុងសំណុំរឿង ០០២/០២**

១. អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកអំពីរបាយការណ៍បណ្តោះអាសន្នរបស់សហមេធាវីនាំមុខ-តំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណងនៅក្នុងសំណុំរឿង ០០២/០២ និង ឧបសម្ព័ន្ធសម្ងាត់ ១ ដែលរៀបរាប់នូវគម្រោងសំណងដែលកំពុងរៀបចំ ដែលបានដាក់នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ (ឯកសារ E352 និង ឯកសារ E352.2 “របាយការណ៍បណ្តោះអាសន្ន”)។ របាយការណ៍បណ្តោះអាសន្នបានជូនដំណឹងដល់អង្គជំនុំជម្រះថា អនុលោមតាមវិធាន២៣*ស្ទួន បួន*(៣)(ខ) សហមេធាវីនាំមុខ និង អង្គភាពគាំពារជនរងគ្រោះ (“VSS”) បានចាប់ផ្តើមដំណើរការពិគ្រោះយោបល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី មេធាវីតំណាងពួកគេ និង ភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីរៀបចំនូវគម្រោងសំណងដែលអាចមានដើម្បីដាក់ជូនអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណានៅពេលបញ្ចប់ការជំនុំជម្រះ។ របាយការណ៍បណ្តោះអាសន្នបានចង្អុលបង្ហាញថា បន្ទាប់ពីការពិគ្រោះយោបល់បន្ថែមទៀតជាមួយដើមបណ្តឹងរដ្ឋប្បវេណី និង

ភាគីពាក់ព័ន្ធដែលត្រូវបានកំណត់ពេលវេលារៀបចំក្នុងខែ កក្កដា ឆ្នាំ ២០១៥ សហមេធាវីនាំមុខនឹងមានលទ្ធភាពប្រសើរក្នុងការផ្តល់អាទិភាពដល់គម្រោងដែលត្រូវដាក់នៅក្នុងការទាមទារសំណងចុងក្រោយរបស់ខ្លួន (ឯកសារ E352)។

២. នៅក្នុងសំណុំរឿង ០០២/០១ ដើម្បីធានាថាកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងការផ្តល់ជាសំណងដល់ជនរងគ្រោះអាចប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និង ដោយសារតែថវិកាមានកំណត់ទាំងនៅផ្នែកសហមេធាវីនាំមុខ និង អង្គភាពគាំពារជនរងគ្រោះនោះ សហមេធាវីនាំមុខត្រូវបានណែនាំឱ្យផ្តល់អាទិភាពដល់គម្រោងសំណងទាំងឡាយដែលអាចយកមកអនុវត្តបាន (ឯកសារ E218/7, E218/7/2, E218/7/4, E218/7/7)។ អង្គជំនុំជម្រះយល់ឃើញថាការអនុវត្តនេះគួរតែបន្តធ្វើនៅក្នុងសំណុំរឿង ០០២/០២ ដែរ។

៣. តាមរយៈសារអេឡិចត្រូនិកដែលមន្ត្រីច្បាប់ជាន់ខ្ពស់បានផ្ញើនៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានសាកសួរទៅសហមេធាវីនាំមុខថា តើពួកគេបានត្រៀមរៀបចំសម្រាប់ធ្វើបទបង្ហាញផ្ទាល់មាត់ស្តីពីគម្រោងសំណងនៅក្នុងសំណុំរឿង ០០២/០២ ហើយ ឬនៅ និង ថាតើពួកគេមានបំណងចង់ដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបន្ថែម ឬជំនួសបទបង្ហាញផ្ទាល់មាត់នាពេលបន្ទាប់ ឬ យ៉ាងណា។ សហមេធាវីនាំមុខបានឆ្លើយតបតាមរយៈសារអេឡិចត្រូនិកនៅថ្ងៃដដែលនោះ ដោយទទួលយកឱកាសក្នុងការធ្វើបទបង្ហាញផ្ទាល់មាត់នៅពេលដើមសប្តាហ៍ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ ដោយត្រូវការពេលវេលាចំនួនមួយវគ្គនៃថ្ងៃសវនាការ។ ពួកគេក៏បានជូនដំណឹងមកអង្គជំនុំជម្រះផងដែរថា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនឹងដាក់ជូននាពេលក្រោយ ក្នុងអំឡុងពេលសម្រាកសវនាការ។

៤. ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសូមណែនាំដល់សហមេធាវីនាំមុខឱ្យរៀបចំនូវបទបង្ហាញផ្ទាល់មាត់ស្តីពីគម្រោងសំណងដែលបច្ចុប្បន្នកំពុងរៀបចំនៅក្នុងសំណុំរឿង ០០២/០២ ដើម្បីធ្វើបទបង្ហាញតាមកាលបរិច្ឆេទមួយដែលនឹងត្រូវកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង តែទំនងជាមិនអាចធ្វើនៅមុន ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ នោះទេ។ អង្គជំនុំជម្រះណែនាំបន្ថែមទៀតទៅសហមេធាវីនាំមុខឱ្យដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរត្រឹមថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦ ដោយមានសេចក្តីបរិយាយលម្អិតអំពីគម្រោងទាំងនេះ ព្រមទាំងគម្រោងពេលវេលាសម្រាប់អនុវត្តន៍ផង។ សហមេធាវីនាំមុខ និង អង្គភាពគាំពារជនរងគ្រោះ

ក៏គួរកំណត់ចំនួនថវិកាគ្រប់គ្រាន់ដែលអាចធានាដល់ការអនុវត្តគម្រោងទាំងនោះផងដែរ (ឯក-សារ E218/7)។ ប្រការនេះស្របទៅនឹងគោលបំណងនៃការអនុម័តវិធាន ២៣*ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុង ដែលអាចអនុវត្តគម្រោងសំណងបានប្រកបដោយអត្ថន័យទៅតាមពេលវេលាសមស្រប ដោយមានការជួយជ្រោមជ្រែងពីម្ចាស់ជំនួយ និង កិច្ចសហការពីមជ្ឈដ្ឋានខាងក្រៅ។

៥. បន្ទាប់ពីបានទទួលព័ត៌មាននេះ អង្គជំនុំជម្រះអាចនឹងស្នើសុំឱ្យមានការបំភ្លឺបន្ថែមទៀតក្នុងករណីចាំបាច់។